ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សត្វព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៥៣

ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩

សាលដីកា

លេខ: ២២ "VIII"

ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០

# សាលដីកា
# តាងនាមប្រជារាស្ត្រខ្មែរ
# តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.លោក [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម

៥.លោកស្រី [redacted] ចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

## តំណាងមហាអយ្យការ

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ២៧២ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ របស់លោក [redacted] សុផល ជាមេធាវីការពារឱ្យជាប់ចោទឈ្មោះ [redacted] សារ៉េន ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៥៨ ក្រ.VII "ភ.ស" ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដែលមាន ៖

-ជនត្រូវចោទឈ្មោះ [redacted] សារ៉េន ភេទស្រី អាយុ៥១ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើតនៅភូមិដូនកឹង ឃុំដូនកឹង ស្រុកកំចាយមារ ខេត្តព្រៃវែង ទីលំនៅមុនពេលឃាត់ខ្លួនភូមិ [redacted]



Scanned with CamScanner

[redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្តីឈ្មោះ [redacted] មានកូនចំនួន០៣នាក់ ជានីតិជន ទោសពីមុនធ្លាប់ជាប់ពន្ធនាគារក្នុងខេត្តព្រៃវែង (ក្នុងឃុំ) ។ (អ្នកប្តឹងសាទុក្ខ)

-ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ២៥៨ ដបឃ.ព្រ១/១៩ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ នៅពន្ធនាគារខេត្តព្រៃវែង ។

មានលោក [redacted] សុផល ជាមេធាវីការពារ ។

<u>ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ:</u> ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ប្រព្រឹត្តនៅភូមិកន្លែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃច្បាប់ភូមិបាល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លាង ភេទប្រុស អាយុ៤៤ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ ។ (ចុងបណ្តឹងសាទុក្ខ)

**អំពីអង្គហេតុះ**

កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង ០២ រសៀល មានការប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត កើតឡើងនៅភូមិកន្លែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ពេលនោះកងកម្លាំងការពារភូមិគ្រឹះ [redacted] បានចុះទៅកន្លែងដីដែលមានទំហំ ១៤៧, ៨៥៧ ម$^{2}$ ជាដីរបស់ឈ្មោះ [redacted] លាង ស្ថិតនៅភូមិកន្លែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ។ ដីនោះមានព្រំប្រទល់ជាប់នឹងឈ្មោះ [redacted] សារ៉េន បានបោះបង្គោលចូលទៅដីរបស់ឈ្មោះ [redacted] លាង ពេលឃើញដូចនេះកងកម្លាំងបានដកបង្គោលចេញឈ្មោះ [redacted] សារ៉េន ក៏ចូលក្នុងផ្ទះ បានទាញកាំភ្លើងម៉ាកអាកា (AK) ស្វ័យវែងមកភ្ជង់ និងគំរាមរកសម្លាប់មកលើកងកម្លាំងការពារនៅទីនោះ ។

-បានឃើញ ដីកាសម្រេចមិនឱ្យនៅក្រៅឃុំបណ្តោះអាសន្នលេខ ៣៦៨០/២០១៩ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រៃវែង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.មិនអនុញ្ញាតឱ្យឈ្មោះ [redacted] សារ៉េន ភេទស្រី អាយុ៥១ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ដូរ មានទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តព្រៃវែង ដែលត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ប្រព្រឹត្តនៅភូមិកន្លែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៥៣ នៃច្បាប់ភូមិបាល នៅក្រៅឃុំជាបណ្តោះអាសន្នឡើយ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១៧ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សុវណ្ណារិទ្ធិ ដែលប្តឹងមិនសុខចិត្តនឹងដីកាសម្រេចមិនឱ្យនៅក្រៅឃុំបណ្តោះអាសន្នលេខ ៣៦៨០/២០១៩ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រៃវែង ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

Scanned with CamScanner

-បានឃើញ សាលដីកាសភាស៊ើបសួរលេខ ៥៧ "ក្រVII.ភស" ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-ទទួលបណ្ដឹងឧទ្ធរណ៍លេខ១៧ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សុវណ្ណារិទ្ធិ ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] សារ៉េន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់ដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំបណ្ដោះអាសន្នលេខ ៣៦៨០/២០១៩ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រៃវែង ទុកជាបានការដដែល ។

សាលដីកានេះ ពិភាក្សាសួរដេញដោលជាអសាធារណៈ និងប្រកាសជាអសាធារណៈ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ ។

បើកសិទ្ធិប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្ដឹងសាទុក្ខលេខ ២៧២ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ របស់លោក [redacted] សុផល មេធាវីការពារជនត្រូវចោទឈ្មោះ [redacted] សារ៉េន ដែលប្ដឹងមិនសុខចិត្តនឹងសាលដីកាសភាស៊ើបសួរលេខ ៥៧ "ក្រVII.ភស" ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្ដីសន្និដ្ឋានសុំថា៖

-យល់ឃើញថា ជនត្រូវចោទឈ្មោះ [redacted] សារ៉េន ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ប្រព្រឹត្តនៅភូមិកន្លែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ២៥៣ នៃច្បាប់ភូមិបាល ។

-យល់ឃើញថា សាលាឧទ្ធរណ៍បានសម្រេចតម្កល់ដីកាសម្រេចលេខ ៣៦៨០/២០១៩ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រៃវែងទុកជាបានការ ដោយលើកសំអាងហេតុថា៖ ការស៊ើបសួរពុំទាន់ជឿនលឿននៅឡើយ បើឱ្យជនត្រូវចោទនៅក្រៅឃុំបណ្ដោះអាសន្ន អាចរាំងស្ទះដល់ការស៊ើបសួរ និងដើម្បីរក្សាខ្លួនជនត្រូវចោទ ទុកជូនចៅក្រមជំនុំជម្រះតាមនីតិវិធី ។ សំអាងហេតុដែលបានលើកឡើងនេះស្របតាមស្មារតីនៃមាត្រា ២០៥ នៃក្រមនីតិវិធីហើយ ។

តំណាងមហាអយ្យការ ស្នើក្រុមប្រឹក្សាជំនុំជម្រះសម្រេច៖

-តំណាងមហាអយ្យការ ទុកជូនក្រុមប្រឹក្សាជំនុំជម្រះសម្រេចតាមច្បាប់ ។

+លោក [redacted] សុផល ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទធ្វើសេចក្ដីសន្និដ្ឋានថា៖ កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ កូនក្ដីខ្ញុំបាទបានស្នើសុំទៅអាជ្ញាធរដើម្បីធ្វើស្ពានីយ៍ប្រេងឥន្ធនៈ ព្រមទាំងធ្វើ



Scanned with CamScanner

របងដើម្បីរក្សាសុវត្ថិភាព បន្ទាប់មកអភិបាលស្រុកក៏បានឯកភាពឱ្យកូនក្តីខ្ញុំសាងសង់ ពេលដែលកូនក្តីខ្ញុំសាងសង់ស្រាប់តែភាគីដើមចោទទៅដកបង្គោលរបងមិនឱ្យកូនក្តីខ្ញុំសាងសង់ ហើយក៏បានប្តឹងមកលើកូនក្តីខ្ញុំ ។ កូនក្តីខ្ញុំមានលិខិតកាន់កាប់ត្រឹមត្រូវ គាត់ធ្វើរបងតែលើដីរបស់ខ្លួនតែប៉ុណ្ណោះ មិនបានចូលទៅក្នុងដីរបស់ដើមបណ្តឹងទេ ទាក់ទងរឿងនេះតុលាការបានចេញដីកាសម្រេចឱ្យនៅក្រៅឃុំបណ្តោះអាសន្ន តែត្រូវគេប្តឹងឱ្យនៅក្នុងឃុំវិញ ទើបកូនក្តីខ្ញុំបាទប្តឹងមកសាលាឧទ្ធរណ៍ កូនក្តីខ្ញុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលអាច នៅក្រៅឃុំជាបណ្តោះអាសន្នបាន ពីព្រោះគាត់មានមុខរបរពិតប្រាកដ មានគ្រួសារ និងមានទីលំនៅច្បាស់លាស់ ។

<u>សំណូមពរ:</u> សូមតុលាការមេត្តាសម្រេចបដិសេធសាលដីកាសាលាឧទ្ធរណ៍ ហើយអនុញ្ញាតឱ្យកូនក្តីខ្ញុំនៅក្រៅឃុំជាបណ្តោះអាសន្ន ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៧២ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ របស់លោក [redacted] សុផល មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] សារ៉េន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា ការដែលសភាស៊ើបសួរសាលាឧទ្ធរណ៍សម្រេចតម្កល់ដីកាសម្រេចលេខ ៣៦៨០/២០១៩ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រៃវែង ទុកជាបានការដដែល ដោយសំអាងថា ជនត្រូវចោទឈ្មោះ [redacted] សារ៉េន ត្រូវបានអយ្យការអមសាលាដំបូងខេត្តព្រៃវែង ធ្វើការចោទប្រកាន់ពីបទ ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត តាមបញ្ញត្តិនៃច្បាប់ភូមិបាល ដែលជាទម្រង់បទល្មើសមជ្ឈិម ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចូលក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមានតម្រុយពិរុទ្ធភាពលើជនត្រូវចោទ ការស៊ើបសួរពុំទាន់មានការជឿនលឿននៅឡើយ បើអនុញ្ញាតឱ្យជនត្រូវចោទនៅក្រៅឃុំ អាចរាំងស្ទះដល់ការស៊ើបសួរ ។ ដូច្នេះ ដើម្បីធានារក្សាជនត្រូវចោទទុកជូនចៅក្រមជំនុំជម្រះចាត់ការតាមនីតិវិធី គប្បីសភាស៊ើបសួរពិចារណាតាមស្មារតីមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នោះ តុលាការកំពូល ពិនិត្យឃើញថា ពុំទាន់មានមូលដ្ឋានគតិយុត្តច្បាស់លាស់នៅឡើយទេ ពីព្រោះថា ដើមបណ្តឹងរដ្ឋប្បវេណីកាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៧ បានដកបង្គោល

Scanned with CamScanner

របងថ្មដែលជនត្រូវចោទបានធ្វើការបោះលើដីដែលជាកម្មសិទ្ធិរបស់ខ្លួន ប៉ុន្តែករណីនេះ មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ បានអះអាងថា ដីដែលកូនក្តីខ្លួនបានបោះបង្គោលរបងថ្មនោះ គឺជាដីកម្មសិទ្ធិរបស់កូនក្តីខ្លួនដូចមានលិខិតបញ្ជាក់កម្មសិទ្ធិចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១០ ដឹងឮពីអាជ្ញាធរភូមិកន្លែងជ្រៅ និងឃុំក្របៅ ។ ដូច្នេះឃើញថា ទាំងភាគីដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាទាំងភាគីជនត្រូវចោទ សុទ្ធតែអះអាងថា ដីទំនាស់នេះជាកម្មសិទ្ធិរបស់ខ្លួនរៀងៗខ្លួន ។ ម៉្យាងវិញទៀត ជនត្រូវចោទជាប់ចោទពីបទប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ប្រព្រឹត្តទៅភូមិកន្លែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២៥៣ នៃច្បាប់ភូមិបាលឆ្នាំ២០០១ គឺជាបទមជ្ឈិមដែលកម្រិតទណ្ឌកម្មអប្បបរមាដាក់ពន្ធនាគារ ០៦ (ប្រាំមួយ) ។ អនុលោមតាមមាត្រា ២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការឃុំខ្លួនជាបណ្តោះអាសន្នមិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមា នៃទោសដែលច្បាប់បានកំណត់ទេ ប៉ុន្តែបើពិនិត្យមើលរយៈពេលឃុំខ្លួនជនត្រូវចោទ បានឃុំខ្លួនបណ្តោះអាសន្នតាមដីកាសម្រេចលេខ ៣៥៦៩ ជសយខ.ព្រទ/១៩ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រៃវែង មកដល់បច្ចុប្បន្នមានរយៈពេលជាង ០៥ ខែហើយ ដូច្នេះគប្បីតុលាការកំពូលអនុវត្តតាមមាត្រា ២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អនុញ្ញាតឱ្យជនត្រូវចោទបាននៅក្រៅឃុំជាបណ្តោះអាសន្ន ។

៣-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៥៧ ក្រ.VII "ភស" ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ដែលបានសម្រេចមកនេះខុសនឹងគតិច្បាប់ ។

## ហេតុដូច្នេះ
## សម្រេច

១-ទទួលបណ្តឹងសាទុក្ខលេខ ២៧២ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ របស់លោក [redacted] សុផល មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] សារ៉េន ។

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ៥៧ ក្រ.VII "ភស" ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ទាំងមូល ។

៣-អនុញ្ញាតឱ្យឈ្មោះ [redacted] សារ៉េន ភេទស្រី អាយុ ៥១ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅបច្ចុប្បន្នភូមិកន្លែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ជាប់ចោទពីបទៈ **ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តទៅភូមិកន្លែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៥៣ នៃច្បាប់ភូមិបាល នៅក្រៅឃុំជាបណ្តោះអាសន្ន ប្រសិនបើជនត្រូវចោទនេះមិនត្រូវបានជាប់ឃុំពីបទល្មើសផ្សេងទៀតទេ ។

Scanned with CamScanner

៤-សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ។

Scanned with CamScanner